# សិលាចារឹកប្រាសាទអូររំដួល K.៦៥៩

## ១- ព័ត៌មានទូទៅ

យើងដឹងព័ត៌មានអំពីប្រាសាទនេះតិចតួចណាស់ តាមរយៈឯកសាររបស់លោក ហ្សឺក សឺដេស ចុះផ្សាយនៅក្នុងឆ្នាំ១៩៥៣។ ឯកសារនោះបង្ហាញថា ប្រាសាទអូររំដួល ជាប្រាសាទមួយស្ថិតនៅក្នុងខេត្តព្រះវិហារ មានចម្ងាយ៥គីឡូម៉ែត្រនៃទិសនិរតីភូមិកន្ទួត និងចម្ងាយ៧គីឡូម៉ែត្រតំបន់ម្លូព្រៃ។[១] តាមរយៈលោក លឹម វណ្ណចន្ទ ដែលធ្លាប់ចុះទៅដល់ទីតាំងសិលាចារឹកនេះ បានឱ្យដឹងថាអ្នកស្រុកបានយកមេទ្វារប្រាសាទនេះទាំងស្រុងចេញពីទីតាំងដើម មករក្សាទុកនៅក្នុងភូមិចារ ឃុំកន្ទួត ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ។ សិលាចារឹកនេះមានចារអត្ថបទចំនួន៣២បន្ទាត់ដែល៣០បន្ទាត់ចារជាភាសាខ្មែរ និង២បន្ទាត់ទៀតចារជាភាសាសំស្ក្រឹត។

អត្ថន័យសំខាន់នៃសិលាចារឹកនេះ គឺព្រះរាជបន្ទូលព្រះមហាក្សត្របញ្ជាឱ្យកំស្តែងអញរាជកុលមហាមន្ត្រីនិងគម្តែងព្រះគ្រូទៅកសាងសិលាចារឹកកត់ត្រាពីស្រុក ស្រែ ភូមិករ ព្រៃថ្វាស ដែលវាបបរមោចារ្យទិញពីចោកស្វាយដើម្បីស្ថាបនាព្រះសិវលិង្គ និងបានបញ្ញត្តិឱ្យមានតែកូនចៅដែលជាអ្នកបួសទើបមានសិទ្ធិគ្រប់គ្រងភោគទ្រព្យរបស់ព្រះ។ ហើយរៀបរាប់ពីគ្រឿងវណ្ណាប់បូជាព្រះ ទ្រព្យផ្តល់ឱ្យព្រះបំនួស អ្នករៀបចំពិធី និងស្តេញបុរោហិតគ្រឿងវណ្ណាប់បូជាសម្រាប់ពិធីបុណ្យមហោស្រពផ្សេងៗ ទេវទ្រព្យ ព្រំប្រទល់ដី ព្រមទាំងឱ្យពរដល់អ្នកដែលចម្រើនបុណ្យនេះនិងដាក់បណ្តាសាដល់អ្នករំលាងបុណ្យ។ នៅក្នុងផ្នែកសំស្ក្រឹត២បន្ទាត់ គឺជាការដាក់បណ្តាសាដល់ជនឯណាដែលមកលួចយកទេវទ្រព្យឱ្យធ្លាក់នរកជាមួយដូនតារបស់ពួកគេ។

ចំពោះស្ថាននាម «ចោកស្វាយ» លោក សឺដេស បានបញ្ជាក់ថាមាននៅក្នុងសិលាចារឹកចំនួនពីរទីតាំងដែលស្ថិតនៅក្នុងតំបន់ជាំក្សាន្ត មានសំណេរជា «ចកស្វាយ»។ សិលាចារឹក

[១] សឺដេស ១៩៥៣។

អត្ថបទដោយ៖ ហ៊ុន ឈុនតេង

ទី១ គឺសិលាចារឹកថ្នល់ស្វាយ (K.៣៤៧) ដែលមានចម្ងាយត្រង់ពីប្រាសាទអូររំដួលប្រមាន ជា៥០គីឡូម៉ែត្រ។ សិលាចារឹកទី២ គឺសិលាចារឹកនៅប្រាសាទកន្ទប់ (ឥឡូវស្គាល់ជាប្រាសាទដូនកៅ K.៣៥២-៣៥៤)។ ទីតាំងប្រាសាទនេះ មានចម្ងាយពីប្រាសាទថ្នល់ស្វាយប្រមាណជា១គីឡូម៉ែត្រប៉ុណ្ណោះ។ យ៉ាងនេះក្តី យើងក៏រកឃើញពាក្យ «ចោកស្វាយ» នេះនៅក្នុងសិលាចារឹកល្បើកស្រុត នៅខេត្តក្រចេះផងដែរ ប៉ុន្តែជាទីតាំងពុំទាក់ទងគ្នានោះឡើយ។ ពាក្យ «ចក» ឬ «ចោក» នេះ ដែលវិវត្តមកជាពាក្យ «ឆោក» ដូចក្នុងពាក្យ «ឆោកគគីរ» ដែលត្រូវគ្នានឹងតំបន់ប្រាសាទកោះកេរជាដើម។ នៅក្នុងការសិក្សាសិលាចារឹកថ្មីមួយមកពីប្រាសាទល្បើកស្រុត-ល្បើកស្រង៉ែ បណ្ឌិត វង់ សុជាព៌ (២០១៦) បញ្ជាក់ថា នៅក្នុងភាសាក្រោល ស្ថិតក្នុងស្រុកសំបូរ ខេត្តក្រចេះ ពាក្យ «ចក» មានន័យថា «អូរ»។

បើពិនិត្យលើការចារអត្ថបទសិលាចារឹកនេះ ជម្រៅចារអក្សរមានលក្ខណៈជ្រៅល្អ ប៉ុន្តែមានតួអក្សរខ្លះចារក្វេច ចារជួស និងចារបន្ថែមក្នុងទំហំតូចៗ តួអក្សរខ្លះ អាចឱ្យយើងច្រឡំដោយងាយ។ នៅក្នុងសិលាចារឹកនេះ ចំណារស្រៈនិស្ស័យ «ិ» និង «ី» បានចោទជាបញ្ហា ដ្បិតសញ្ញាទាំងពីរនេះ ហាក់ឱ្យយើងបែងចែកគ្នាពុំដាច់ឡើយ។ ចំណែកឯអំណានរបស់លោក សឺដេស គឺលោកបានពឹងផ្អែកលើអំណានពាក្យដែលធ្លាប់ជួបប្រទះ និងពាក្យដើមនៅក្នុងភាសាសំស្ក្រឹត ទោះបីអំណានដែលមានស្រៈ «ិ» និងស្រៈ «ី» មានសញ្ញាដូចគ្នាក្តី។ ត្រង់អំណានពាក្យខ្លះ ស្រៈ «ិ» ឬស្រៈ «ី» មានរូបរាងដូចជាសក់របស់ព្យញ្ជនៈទៅវិញ ដូចជាពាក្យ «បិ» នៅបន្ទាត់ទី៦ ជាដើម។ ដោយផ្អែកតាមរូបសញ្ញា យើងសម្រេចកំណត់រូបសញ្ញាស្រៈមានរាងវង្វង់ក្ងួចបន្តិចឬពុំក្ងួចសោះ គឺជាស្រៈ«ិ» និងសញ្ញាស្រៈដែលមានកំណួចខ្លាំង ជាស្រៈ «ី»។ ចំពោះសញ្ញាលេខវិញ លេខ១ មានរូបសញ្ញាស្រដៀងនឹងអក្សរ «រ»។

## ២- អត្ថបទដើមជាអក្សរទំនើប

១- ០៨៨២គក•គី[២]នូស្តាបនាវ្រះកំម្រតេងអញ

[២] លោក សឺដេស អានជា «គិ»។

២- គីវលីង្គ[៣]·៨៩០គកម្វាយិកេតិភាទ្រុបទតោយិច

៣- ទ្រុមាសវុទ្ធវារបូវ្ងផាល្គុណី[៤]នក្សត្រនូមានិវ្រះគា

៤- សនធូលីវ្រះបាទធូលិជេងវ្រះកំម្រតេង៑[៥]អញគ្រីជយវម្ម៌

៥- ទេវតកំស្តេងអញរាជកូលមហាមាន្ត្រី[៦]តកំម្រតេង៑[៧]អញ

៦- វ្រះគុរុបិ[៨]ប្រេទៅស្ថាបនាប្រគស្តតគិស្រូកិស្រេភូម្យា

៧- ករវ្រៃថ្វាសិតតិវាបិបរមាចាយ៌្យដៅវតចោកិស្វាយិ

៨- បិ[៩]ស្វំវ្រះករុណាប្រសាទបីស្ថាបនាគីពលិង្គ[១០]ស្ថាបនាវ្រះ

៩- បយ៌្យង៑សំគណានូកំម្រតេង៑ជគតិលីង្គបូរនាំវ្រះប

១០- យ៌្យង៑ទៅម្វាយិវត្តម្វាយិឆ្នាំថ្វាយិវ្រះភោគវ្ងំជាស្វតន្ត្រ

១១- តវ្រីហវ្ងំជាបិ[១១]ស្វតន្ត្រតកន្វារិប្រំ/ប្រលោ[១២]វ្ងំជាបិស្វតន្ត្រត

១២- ភូតាគតបញ្ចូល[១៣]ផោង៑វ្ងំជាបីអាយត្តតកូលេក្វ

[៣] លោក សឺដេស អានជា «គិវលិង្គ»។

[៤] លោក សឺដេស អានជា «ផាល្គុណិ»។

[៥] លោក សឺដេស អានជា «កម្រតេង៑»។

[៦] លោក សឺដេស អានជា «មហាមន្ត្រិ»។

[៧] លោក សឺដេស អានជា «កម្រតេង៑»។

[៨] ត្រង់សំណេរនេះ ស្រៈ «ិ» អាចភ្ជាប់មានរូបរាងដូចសក់នៅផ្នែកខាងឆ្វេង ឬចារក្វេច។

[៩] ត្រង់សំណេរនេះ ស្រៈ «ិ» អាចភ្ជាប់មានរូបរាងដូចសក់នៅផ្នែកខាងឆ្វេង ឬចារក្វេច។

[១០] លោក សឺដេស អានជា «សិវលិង្គ»។

[១១] ត្រង់សំណេរនេះ ស្រៈ «ិ» អាចភ្ជាប់មានរូបរាងដូចសក់នៅផ្នែកខាងឆ្វេង ឬចារក្វេច។

[១២] លោកសឺដេស អានជា «ប្រំលោ»។ ជាទូទៅ ពាក្យនេះឃើញមាននៅលើសិលាចារឹកផ្សេងៗទៀតជា «ប្រលោ»។ ម្យ៉ាងវិញទៀត នៅលើផ្ទាំងថ្ម យើងពុំឃើញមានចំណារស្រៈ «ំ» ឡើយ ប៉ុន្តែមានស្នាមតូចមួយដែលអាចនាំឱ្យច្រឡំនឹងស្រៈ «ំ» នៅលើសំណៅផ្តិត។

[១៣] លោកសឺដេស អានជា «បញ្ចូលិ»។

អត្ថបទដោយៈ ហ៊ុន ឈុនតេង

១៣- និចៅតបំន្វាស្មី[14]បិត្យងិជាម្ម៉បីប[15]រិ[16]បាលគិ[17]ធម្ម[18]គិតអាចិមា

១៤- និគូសិនេះគីពោះក[[ល្ប]]នាយាជមាន[19]រង្កោតជាយជ្វជេ១

១៥- ប្រតិទីនក្រិយាស្រោងិប្រតីទីនបញ្ចគវ្យឃ្លុតមធូទជិក្សីរ

១៦- គូទនារីកេល[20]•គន្ធានូលេបន•ទីបធូបតាម្វូល[21]ក្រមូកផល•

១៧- តួយ៉្យតីងតោងិរាំច្រ្យងិគន្ធវ៌្វហ្វូទូកគិខរា◦នីវន្ធវ្រះបំ

១៨- ន្វសិស្មីងិស្តេញបូរោហិត[22]ស្រុថ្ងងិ៦ចន្ទ្យាកិយោ១តូ្វងិ

១៩- តែំ១ស្វាតែំ២ស្តេងិតបូជាតវ្យរ[23]អំបលិស្តេងិត(បូ)រោហីត[24]ឧក្កមី

២០- ម្វាយិអ្នាក៊[25]ស្តេញិការិតវ្យរចន្ទ្យាកិវ្ះ១ស្រុថ្ងងិ២ជេ២មីម្វាយិ

២១- អ្នាក៊[26]ស្រេវរហិថ្ងងិ២ជេ២មីម្វាយិស្មីងិ•តគិឧត្សវជោងិចំរេ

២២- និរង្កោជេ២ក្រីយាហោមជោងិ•ទេវទ្រវ្យ•មាសិប្រាក៊ស្វោក៊

២៣- រៅទិបទីគះកទាហកមន្ទលូបង្កបិថ្មុរក្របីតំយ៉្យខ្ញុំតបំ

២៤- រទំនេប្របមេកិមហានសបត្រការអំរះអ្នាក[27]ស្រេផ្សំមិ

២៥- ខ្ញុំជោងិ៤០-១០-៨ភូម្យតីបូវ៌្វប្រសបិអគ្រន្ធសារតីទក្សិន

---

[14] ស្រៈ «ី» ចារនៅទីតាំងសក់ស មានរូបរាងធំជាងសក់សបន្តិច ដែលអាចនាំឱ្យយើងច្រឡំជាសក់ស។

[15] អក្សរ «ប» ក្នុងពាក្យ «បរិបាល» ជួសបន្ថែមនៅខាងលើ ចន្លោះអក្សរ «បិ» និង «រិ»។

[16] ស្រៈ «ិ» មានរូបរាងដូចសក់រ។

[17] «គិ» មានរូបរាងស្រដៀងស្រៈ «ត»។

[18] អក្សរ «ម» ភ្លេចវះពោះ នាំឱ្យមានរូបរាងដូចអក្សរ «ប»។

[19] លោក សឺដេស អានជា «យជមាន»។

[20] លោក សឺដេស អានជា «នារិកេល»។

[21] លោក សឺដេស អានជា «តាម្ពូល»។

[22] លោក សឺដេស អានជា «បុរោហិត»។

[23] លោក សឺដេស បន្ថែមសញ្ញា «•» ដែលយើងពុំឃើញមាននៅលើផ្ទាំងថ្ម។

[24] នៅលើផ្ទាំងថ្ម ពាក្យនេះចារជា «បរោហិត» ភ្លេចស្រៈ «ុ»។

[25] លោក សឺដេស អានជា «អ្នក៊»។

[26] លោក សឺដេស អានជា «អ្នក៊»។

[27] លោក សឺដេស អានជា «អ្នក៊»។

អត្ថបទដោយៈ ហ៊ុន ឈុនតេង

AMS អរិយធម៌ខ្មែរ

២៦- ប្រសបិវ្រៃស្វូកេតថ្នាគោលិតីបត្នីមប្រសបិជម្ទ័លថ្នាផ្ទុ

២៧- តទិង្ធ•តីឧត្ដរថ្នាគោលិប្រសបិចោកិស្វាយ•នេះគិពោហរ

២៨- រគាបវ្រ៉ាហ្មអាចាយ៌្យបន្ទីតយជមាននៅសាធ្វ[២៨]តអា

២៩- ចិរទ្វ័យនេះបូន្យនេះគេមានិស្វគ្គ៌•នៅគេតលោបេ

៣០- បូន្យនេះគេមានិបាប

៣១- យេតាន្យបហរន្តីហ ហីពយន្តិធនានិច

៣២- តេយាន្តិបិត្ធកិស្យាទ្ធិំ ពៅវាទៀម្វ[២៩]យាតនាមិ

## ៣- អត្ថបទប្រែសម្រួល

(១-២) ៙មហាសករាជឆ្នាំ៨៨២(គ.ស.៩៦០) គឺ(ជាវេលា)ស្ថាបនាព្រះកម្តែងអញ សិវលិង្គ។

(២-១៤) មហាសករាជឆ្នាំ៨៩០(គ.ស.៩៦៨) ១កើត ខែកទ្រឹបទ តាមខែចន្ទគតិ ថ្ងៃពុធ នក្សត្របូព៌ផល្គុណី នូវមានព្រះរាជសាសន៍ធូលីព្រះបាទធូលីជើងព្រះកម្តែងអញស្រីជ័យវម៌្មទេវ(ទី៥) (ត្រាស់បញ្ជា)ដល់កំស្តែងអញរាជកុលមហាមន្ត្រី (និង)ដល់កម្តែងអញព្រះគ្រូ ដើម្បីប្រើទៅស្ថាបនាសិលាចារឹក គឺ(កត់ត្រាអំពី)ស្រុក ស្រែ (និង)ភូមិករព្រៃថ្វាស ដែលវាបបរមោចារ្យជាវពីចោកស្វាយដើម្បីសុំព្រះរាជទានស្ថាបនាព្រះសិវលិង្គ ស្ថាបនា(ការផ្គត់ផ្គង់)ព្រះប្រេង ចូលរួមផ្សំជាមួយនឹងកម្តែងជគតលិង្គបូរ(គឺប្រាសាទកោះកេរ)។ នាំយកព្រះប្រេងទៅមួយឆ្នាំម្តង ថ្វាយ(ជា)ព្រះភោគទ្រព្យ។ (ព្រះភោគទ្រព្យនេះ)ពុំស្ថិតក្រោមការគ្រប់គ្រងរបស់(ខ្លោញ)ស្រូវ ពុំស្ថិតក្រោមការគ្រប់គ្រងរបស់កន្ទ្វារប្រលោ ពុំស្ថិតក្រោមការគ្រប់គ្រងរបស់ភូតាសប្រេងល្ហុងខ្វងទាំងឡាយ ពុំគប្បីស្ថិតនៅក្រោមចំណុះរបស់ក្រុមគ្រួសារ(អ្នកទាំងនោះ)ឡើយ។ (រីឯ)កូនចៅដែលជាអ្នកបួស គប្បីដឹងពីធម៌ គប្បីថែរក្សាធម៌ ទើបអាចគ្រប់គ្រងព្រះភោគទ្រព្យទាំងអស់នេះ។

[២៨] លោក សឺដេស អានជា «សាធុ»។

[២៩] លោក សឺដេស អានជា «ពៅវាទៀមុយាតនាមិ»។

(១៤-១៧) នេះគឺគ្រឿងវណ្ណាប់បូជារបស់អ្នកធ្វើទាន (ក្នុងនោះមាន) អង្ករជា(គ្រឿងបូជា)យញ្ញ១ដើរៀងរាល់ថ្ងៃ ក្រយាស្រង់រៀងរាល់ថ្ងៃ បញ្ចគោរស(=ទឹកដោះគោ៥យ៉ាង) ឃ្មុត(ប៉័រទឹកដោះគោ) ទឹកឃ្មុំ ទឹកដោះគោរជូរ ទឹកដោះគោស្រស់ រង្វ ផ្លែដូង គ្រឿងក្រអូប និងគ្រឿងលាប ប្រទីប ធូប ម្ទូ ស្លា គ្រឿងភ្លេងដេញនិងទូង (អ្នក)រាំ (អ្នក)ច្រៀង គន្ធព្វ(=គ្រឿងភ្លេងខ្សែម្យ៉ាង/ពួកគន្ធព្វ) ស្គរហុឌុក្កា (និង)សិខរា(=គ្រឿងភ្លេងខ្សែម្យ៉ាង)។

(១៧-២១) ផ្តល់ឱ្យព្រះបំនួស អ្នករៀបចំពិធី (និង)ស្តេញបុរោហិត(នូវ)ស្រូវ៦ថ្លឹងសម្លៀក១យៅ ដូង១ដើម ស្លា២ដើម (និង)ស្តេងដែលជាអ្នកបូជា២នាក់, (ផ្តល់ឱ្យ)អម្បាលស្តេងដែលជាបុរោហិតផងក្នុងម្នាក់ៗ ស្តេញការី(អ្នកធ្វើការ)២នាក់ (នូវ)សម្លៀក១បន្ទាស់ស្រូវ២ថ្លឹង២ដើ ក្នុងម្នាក់ៗ, ស្រែព្រោះ២ថ្លឹង ២ដើ(ដល់) (សម្រាប់)អ្នករៀបចំពិធីបូជាម្នាក់ៗ។

(២១-២២) នៅពេលមានពិធីបុណ្យមហោស្រពនានា ចម្រើនអង្ករ២ដើ (និងផ្តល់)ក្រយាហោមផង។

(២២-២៥) ទេវទ្រព្យ(រួមមាន) មាស ប្រាក់ ស្ពក ថូរៅទិ បទិគះ(កន្ថោរស្ពោះ) ខ្ទះ ថូកមណ្ឌលុ កាំបិតបង្កាប់ គោ ក្របី ដំរី អ្នកបម្រើដែលធ្វើការដូចជាអ្នកបើក(ទ្វារ) ចុងភៅ អ្នកក្រងស្លឹក អំរះ (និង)អ្នកធ្វើស្រែ។ សរុបអ្នកបម្រើទាំងអស់៥៨នាក់។

(២៦-២៨) ដីភូមិ ខាងកើតប្រសព្វអគ្រន្ធសារ ខាងត្បូងប្រសព្វព្រៃសូភេតត្រង់ថ្មគោល ខាងលិចប្រសព្វជម្ពុលត្រង់ផ្លូវទទឹង(ថ្ងៃ) ខាងជើងត្រង់ថ្មគោលប្រសព្វចោកស្វាយ។

(២៥-៣០) នេះគឺពរនិងបណ្តាសា។ (នូវ)ព្រាហ្មណ៍ អាចារ្យ បណ្ឌិត អ្នកធ្វើទាន និងសាធុជនទាំងឡាយ ដែលអាចចម្រើនបុណ្យនេះ អ្នកនោះនឹងទៅកាន់ឋានសួគ៌។ នូវអ្នកដែលរំលាងបុណ្យនេះ អ្នកនោះនឹងមានបាប។

(៣១-៣២) សូមឱ្យអ្នកទាំងឡាយណាដែលយក និងនាំអ្នកឯណាមកលួចយកទ្រព្យធនទាំងនេះ ធ្លាក់ជាមួយនឹងដូនតាគេទៅកាន់នរកនានា មាននរកពោរពជាដើម៕

អត្ថបទដោយៈ ហ៊ុន ឈុនតេង

# ឯកសារពិគ្រោះ

វង់ សុផារ៉

២០១៦. សិលាចារឹកនៃប្រទេសកម្ពុជាសម័យអង្គរ. ការផ្សាយលើកទ២។

Cœdès, G.

1953. Piédroit of Pràsàt Ó Roṃduol (K. 659) in *Inscriptions du Cambodge*, Vol. 5. Paris.

Jenner, P.

Piédroit of Pràsàt Ó Roṃduol in Part xml, № 62. http://sealang.net/ok/corpus.htm

## បញ្ជីរូបភាព



មេទ្វារប្រាសាទ ដែលអ្នកស្រុកយកចេញពីទីតាំងដើមមករក្សាទុក (រូបថត៖ លឹម វណ្ណចន្ទ័)

អត្ថបទដោយ៖ ហ៊ុន ឈុនតេង



រូបថតសិលាចារឹកប្រាសាទអូររំដួល (រូបថតៈ លឹម វណ្ណចន្ទ)



រូបថតសិលាចារឹកប្រាសាទអូររំដួល (រូបថតៈ លឹម វណ្ណចន្ទ)

អត្ថបទដោយៈ ហ៊ុន ឈុនតេង



រូបថតសិលាចារឹកប្រាសាទអូររំដួល (រូបថត៖ លឹម វណ្ណច័ន្ទ)



រូបថតសិលាចារឹកប្រាសាទអូររំដួល (រូបថត៖ លឹម វណ្ណច័ន្ទ)

អត្ថបទដោយ៖ ហ៊ុន ឈុនតេង